**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៧០ អនក្រ.បក**

# អនុក្រឹត្យ
## ស្តីពី
## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ និងបំពេញបន្ថែមមាត្រា៣៤ ថ្មីស្ទួន និងមាត្រា៣៩ ស្ទួន របស់អនុក្រឹត្យលេខ២៧៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ១០៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីសមត្ថកិច្ចនិងតួនាទីភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងារអត្រានុកូលដ្ឋាន ស្របតាមច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការងារអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅតាមស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

## ជំពូកទី២
## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ
### ផ្នែកទី១
### មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

**មាត្រា៣.-**

អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ គឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

ក្នុងករណីអគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មអវត្តមាន អគ្គនាយករងដែលទទួលសិទ្ធិជាអគ្គនាយកស្តីទី មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

## ជំពូកទី២
## ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ

**មាត្រា៤.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ មានភារកិច្ចដូចខាងក្រោម៖

ក- គ្រប់គ្រងនិងរក្សាទុកបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានអនុវត្តរួច។

ខ- ធានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាស្ដីពីអត្រានុកូលដ្ឋានដែលស្ថិតនៅក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

គ- ដាក់ចេញគោលការណ៍ សេចក្ដីណែនាំ និងបែបបទនិងនីតិវិធី ស្របតាមការកំណត់ក្នុងបទប្បញ្ញត្តិនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ឃ- ត្រួតពិនិត្យ និងណែនាំដល់មន្ត្រីអត្រានុកូលដ្ឋានគ្រប់ថ្នាក់ រួមទាំងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស លើការអនុវត្តការងារអត្រានុកូលដ្ឋាន។

ង- អភិវឌ្ឍផែនការ និងផ្ដល់ការបណ្ដុះបណ្ដាលដល់មន្ត្រីអត្រានុកូលដ្ឋាន។

ច- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ផ្ដល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។

ឆ- រាយការណ៍រាល់ករណីរំលោភបទប្បញ្ញត្តិច្បាប់ដែលប្រព្រឹត្តដោយមន្ត្រីអត្រានុកូលដ្ឋាន ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីចាត់វិធានការតាមច្បាប់។

ជ- ពិនិត្យសម្រេច និងអនុញ្ញាតឱ្យកែតម្រូវទិន្នន័យអត្រានុកូលដ្ឋាន ឬអនុញ្ញាតឱ្យចុះបញ្ជីអត្រានុកូលដ្ឋានឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ឈ- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ផ្សេងទៀតមិនអាចសម្រេចបាន។

ញ- ពិនិត្យ និងសម្រេចអនុញ្ញាតឱ្យចុះបញ្ជីអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស នៅថ្នាក់ឃុំ សង្កាត់ នៃលំនៅឋានរបស់សាមីខ្លួនជាប្រជាពលរដ្ឋខ្មែរ។

ដ- ពិនិត្យ និងសម្រេចលើបណ្ដឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

ឋ- ពិនិត្យ និងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់របស់បុគ្គល ដែលបានទទួលព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែរទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងចេញសេចក្ដីចម្លងសំបុត្រកំណើត។

ឌ- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ ក្នុងករណីដែលមានការស្នើសុំ។

ឍ- ចេញសម្រង់បញ្ជីកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ណ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមឡើងវិញ ក្នុងករណីខូចខាត ឬបាត់បង់ ឬកែតម្រូវទិន្នន័យ។

គ- ក្នុងករណីចាំបាច់ ស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការបង្កើតការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាននៅមូលដ្ឋានសុខាភិបាល ឬកន្លែងផ្សេងទៀតដែលព្រឹត្តិការណ៍ជីវិតអាចកើតឡើង ដោយរៀបចំឱ្យមានបុគ្គលិកអត្រានុកូលដ្ឋាន ឬធ្វើប្រតិភូកម្មភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន ទៅឱ្យមន្ត្រីសុខាភិបាល។

ឋ- អនុវត្តសេចក្តីសម្រេចរបស់តុលាការលើការងារអត្រានុកូលដ្ឋាន។

ទ- ពិនិត្យ និងសម្រេចកែតម្រូវទិន្នន័យ ឬមោឃភាពបញ្ជីអត្រានុកូលដ្ឋានឱ្យមានសង្គតិភាពទិន្នន័យនៃអត្តសញ្ញាណបុគ្គលជាមួយឯកសារអត្តសញ្ញាណផ្សេងៗទៀត ដើម្បីធានាឱ្យមនុស្សម្នាក់មានអត្តសញ្ញាណតែមួយ។

## ជំពូកទី៣

## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

### ផ្នែកទី១

### មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

**មាត្រា៥.-**

អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

ក្នុងករណីអភិបាល នៃគណៈអភិបាលរាជធានី ខេត្តអវត្តមាន អភិបាលរងដែលទទួលសិទ្ធិជាអភិបាលស្ដីទី នៃគណៈអភិបាលរាជធានី ខេត្ត មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

### ផ្នែកទី២

### ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត

**មាត្រា៦.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍តាមការស្នើសុំ។

ខ- ចេញសម្រង់បញ្ជីកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋានដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាស្ដីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ង- អភិវឌ្ឍផែនការ និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ច- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។

ឆ- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីដែលមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មិនអាចសម្រេចបាន។

ជ- ពិនិត្យ និងសម្រេចលើបណ្ដឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

## ជំពូកទី៤
## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ
### ផ្នែកទី១
### មន្ត្រីអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌ

**មាត្រា៧.-**

អភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

ក្នុងករណីអភិបាល នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌអវត្តមាន អភិបាលរង ដែលទទួលសិទ្ធិជាអភិបាលស្ដីទី នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិអំណាចទទួលខុសត្រូវជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត។

### ផ្នែកទី២
### ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌ

**មាត្រា៨.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម៖

ក- ចេញសេចក្ដីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ខ- ចេញសម្រង់បញ្ជីកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

គ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ឃ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើមឡើងវិញ ក្នុងករណីខូចខាត បាត់បង់ ឬកែតម្រូវទិន្នន័យ។

ង- តាមដាន ត្រួតពិនិត្យ និងគាំទ្រការអនុវត្តការងាររបស់មន្ត្រីអត្រានុកូលដ្ឋាន ថ្នាក់ឃុំ សង្កាត់ ដើម្បីធានានាការអនុវត្តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាស្ដីពីអត្រានុកូលដ្ឋាន ដែលស្ថិតនៅក្រោមច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

ច- គាំទ្រ និងពង្រឹងសមត្ថភាពដល់មន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ឆ- ជំរុញឱ្យមន្ត្រីអត្រានុកូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ផ្ដល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវតាមការកំណត់។

ជ- ពិនិត្យ និងសម្រេចលើការចុះបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់មិនអាចសម្រេចបាន។

ឈ- ពិនិត្យ និងសម្រេចលើបណ្ដឹងមិនសុខចិត្តនឹងការចាត់ចែង រួមទាំងសេចក្ដីសម្រេច ឬការយឺតយ៉ាវ ឬការធ្វេសប្រហែសក្នុងការចាត់ចែងរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន។



ɣ

ញ- អនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ និងសេចក្តីសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន។

## ជំពូកទី៥
## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់
### ផ្នែកទី១
### មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

**មាត្រា៩.-**

មេឃុំ ចៅសង្កាត់ ជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ក្នុងដែនសមត្ថកិច្ចដែលខ្លួនគ្រប់គ្រង។

ក្នុងករណីមេឃុំ ចៅសង្កាត់អវត្តមាន មេឃុំ ចៅសង្កាត់ ត្រូវប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកជំនួយការមេឃុំ ចៅសង្កាត់តាមឋានានុក្រម និងត្រូវរាយការណ៍ជាផ្លូវការជូនមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ។

ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមានដោយសារមរណភាព ឬការបញ្ឈប់មុខតំណែងក្នុងរយៈពេលអន្តរកាលដែលមិនទាន់មានការតែងតាំងមេឃុំ ចៅសង្កាត់ថ្មី មេឃុំ ចៅសង្កាត់ស្តីទីគឺជាមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់។

### ផ្នែកទី២
### ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់

**មាត្រា១០.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ មានភារកិច្ចដូចខាងក្រោម៖

ក- ពិនិត្យ និងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើម និងសេចក្តីចម្លង។

គ- ចេញសម្រង់បញ្ជីកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ឃ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ង- ផ្តល់ការអនុញ្ញាតសម្រាប់ការបូជាសព ឬការបញ្ចុះសព។

ច- កត់ត្រា កែតម្រូវ ឬធ្វើមោឃភាពបញ្ជីអត្រានុកូលដ្ឋាន តាមសេចក្តីសម្រេចជាស្ថាពររបស់តុលាការ និង/ឬទៅតាមការសម្រេចរបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ដែលមានអានុភាពអនុវត្ត។

ឆ- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។

ជ- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន មន្ត្រីសុខាភិបាល មន្ត្រីអប់រំ មន្ត្រីសង្គមកិច្ច និងមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត អំពីការងារអត្រានុកូលដ្ឋាន ក្នុងករណីចាំបាច់។

ឈ- ចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីសម្រេចឱ្យបាននូវការចុះបញ្ជីអត្រានុកូលដ្ឋានពេញលេញ។

ញ- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវទៅតាមការកំណត់។

## ជំពូកទី៦
## សមត្ថកិច្ចនៃមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា
### ផ្នែកទី១
### មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា១១.-**

រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវចាត់តាំងមន្ត្រី ១(មួយ)រូប ជាមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស និងត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីការចាត់តាំងនេះ។

**មាត្រា១២.-**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីបណ្តុះបណ្តាលមន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងដែលទើបតែងតាំងថ្មី មុនអនុញ្ញាតឱ្យបំពេញភារកិច្ចជាមន្ត្រីអត្រានុកូលដ្ឋាន។

### ផ្នែកទី២
### ភារកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា១៣.-**

មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចខាងក្រោម៖

ក- ពិនិត្យនិងកត់ត្រាព័ត៌មានចាំបាច់នានាទាក់ទងនឹងកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍។

ខ- ចេញសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ច្បាប់ដើម និងសេចក្តីចម្លង។

គ- ចេញសម្រង់បញ្ជីកំណើតរស់ មរណភាព និងអាពាហ៍ពិពាហ៍ តាមការស្នើសុំ។

ឃ- កែតម្រូវកំហុសនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ដែលជាសមត្ថកិច្ចរបស់មន្ត្រីអត្រានុកូលដ្ឋាន យោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឬលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

ង- ចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅក្នុងដែនសមត្ថកិច្ចរបស់ស្ថានតំណាងនីមួយៗ ដើម្បីសម្រេចឱ្យបាននូវការចុះបញ្ជីអត្រានុកូលដ្ឋានពេញលេញ។

ច- សហការជាមួយរដ្ឋម្ចាស់ផ្ទះក្នុងការផ្តល់ឯកសារពាក់ព័ន្ធនានាសម្រាប់បូជាសព ឬបញ្ចុះសពរបស់ពលរដ្ឋខ្មែរ ឬបញ្ជូនសពពលរដ្ឋខ្មែរត្រលប់មកព្រះរាជាណាចក្រកម្ពុជា

ឆ- ផ្តល់របាយការណ៍អត្រានុកូលដ្ឋានឱ្យបានទៀងទាត់ និងត្រឹមត្រូវទៅតាមការកំណត់ទៅមន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា១៤.-**

មន្ត្រីអត្រានុកូលដ្ឋានប្រចាំស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស ត្រូវអនុវត្តការងារអត្រានុកូលដ្ឋាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ព្រមទាំងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសេចក្តីណែនាំនានារបស់មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ។

## ជំពូកទី៧
## ការប្រើប្រាស់ត្រារបស់មន្ត្រីអត្រានុកូលដ្ឋាន

**មាត្រា១៥.-**

មន្ត្រីអត្រានុកូលដ្ឋានថ្នាក់ជាតិ ត្រូវប្រើប្រាស់ត្រារបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។

មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់រាជធានី ខេត្ត ត្រូវប្រើប្រាស់ត្រារបស់រដ្ឋបាលរាជធានី ខេត្ត។

មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវប្រើប្រាស់ត្រារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

មន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ឃុំ សង្កាត់ ត្រូវប្រើប្រាស់ត្រារបស់រដ្ឋបាលឃុំ សង្កាត់។

មន្ត្រីអគ្រានុកូលដ្ឋានប្រចាំស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់ត្រារបស់ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបរទេស។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា១៦.-**

អនុក្រឹត្យលេខ១៣៤ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីមន្ត្រីអគ្រានុកូលដ្ឋានថ្នាក់ជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១១ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អគ្គសេនាបតីបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ